ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៩..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលប្រធានគណៈកម្មការស្រាវជ្រាវអំពើហិង្សា ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញសេចក្តីសម្រេចលេខ០៣ស.សរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវអំពើហិង្សា ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣

-ផ្អែកតាមការចាំបាច់

**សំរេច**

**ប្រការ១:** ត្រូវបានតែងតាំងឯកឧត្តម ឧត្តមនេសីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ ជាប្រធាននៃគណៈកម្មការស្រាវជ្រាវអំពើហិង្សា ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិ ប្រជាពលរដ្ឋ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ ជំនួសឯកឧត្តមឧត្តមសេនីយ៍ទោ**ឃួ ស៊ុនឡុង** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស គ្រប់ប្រធានក្រសួង ស្ថាប័ន និងឯកឧត្តម អស់លោកក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែកុម្ភៈ ឆ្នាំ២០០៣

**ជ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

សស ១០៦

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីស ខេង*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងការពារជាតិ*
- *អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ*
- *អគ្គស្នងការដ្ឋាននគរបាលជាតិ*
- *បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*
- *ដូចប្រការ១*
- *ឯកសារ-កាលប្បវត្តិ*